ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
លេខ......៦៥០.......បទ.ប្រក.............

និយ័តករទូរគមនាគមន៍កម្ពុជា
ចូល លេខ 1646 ន.ទ.ក
ថ្ងៃទី 26 ខែ 07 ឆ្នាំ២០18
ម៉ោង 11:30 បញ្ជូន

នាយកដ្ឋាននិយ័តកម្មទូរគមនាគមន៍
ចូល លេខ 0879 ន.ន.ទ
ថ្ងៃទី 30 ខែ 07 ឆ្នាំ២០18
ម៉ោង ៩:០០ព្រឹក អ្នកទទួល

# ប្រកាស
## ស្តីពី
## បែបបទ និងនីតិវិធីនៃការផ្តល់ព័ត៌មានអំពីការសាងសង់ ដំឡើង រុះរើ ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ នៅតាមភូមិសាស្ត្រខេត្ត

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ២៦, មាត្រា ២៧, មាត្រា ២៨ និងមាត្រា ២៩ និងបំពេញបន្ថែមមាត្រា ២៩ ស្ទួន នៃអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញប្រកាសលេខ ១២៦ បទ.ប្រក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅរបស់នាយកដ្ឋាន មជ្ឈមណ្ឌល និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានប្រៃសណីយ៍ និង ទូរគមនាគមន៍
- យោងតាមការចំបាច់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណង និងគោលដៅកំណត់បែបបទ និងនីតិវិធីនៃការផ្តល់ព័ត៌មានអំពីការសាងសង់ ដំឡើង រុះរើ ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍នៅក្នុងភូមិសាស្ត្រខេត្ត ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង ការពង្រឹងសុវត្ថិភាព សោភ័ណ្ឌភាព និងការការពារបរិស្ថាន។



អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ (៨៥៥) ២៣-៧២៤៨១០/៤២៦៥១០
ទូរសារ (៨៥៥) ២៣-៧២៤០៦៩

**ប្រការ ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ប្រតិបត្តិករទូរគមនាគមន៍ និងក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណិត (ISP) ដែលធ្វើការសាងសង់ ដំឡើង រុះរើ ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍នៅតាមភូមិសាស្ត្រខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

ពាក្យបច្ចេកទេសដែលប្រើក្នុងប្រកាសនេះមានដូចខាងក្រោម៖

- គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ សំដៅដល់ សម្ភារៈបរិក្ខារ ឧបករណ៍ គ្រឿងបង្គុំ ឬបរិយាកាសណ្ឌ ដែលត្រូវបានផលិត និង/ឬនាំចេញ ឬនាំចូល យកមកប្រើប្រាស់ក្នុងប្រព័ន្ធទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ។
- ទូរគមនាគមន៍ សំដៅដល់វិទ្យាសាស្ត្រ និងបច្ចេកទេសក្នុងការបញ្ជូន និងទទួលស៊ីញ៉ាល់ ទិន្នន័យ សំឡេង រូបភាព ឬប្រភេទព័ត៌មានដទៃទៀត តាមរយៈការប្រើប្រាស់ថាមពលក្រោមទម្រង់អេឡិកត្រូម៉ាញ៉េទិក អគ្គិសនី វិទ្យុ ពន្លឺ ឬទម្រង់ផ្សេងៗទៀត។
- ហេដ្ឋារចនាសម្ព័ន្ធ ទូរគមនាគមន៍ រួមមាន៖ ស្ថានីយ៍សម្រាប់ដំណើរការទូរស័ព្ទចល័ត(BSC, BTS, BWA, MSC...) មជ្ឈមណ្ឌលទូរស័ព្ទអចល័ត(Switching Center) ស្ថានីយ៍វិទ្យុបន្ត (Microwave) បណ្តាញខ្សែកាប្លិ៍ទូរគមនាគមន៍គ្រប់ប្រភេទ (ខ្សែកាប្លិ៍ទង់ដែង ខ្សែកាប្លិ៍អុបទិក និងប្រព័ន្ធខ្សែកាប្លិ៍ក្រោមបាតសមុទ្រ) ។

**ប្រការ ៤.-**

ប្រតិបត្តិករទូរគមនាគមន៍ និងក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណិត ត្រូវផ្តល់ព័ត៌មានទៅមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត អំពីការសាងសង់ ដំឡើង រុះរើ ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍នៅតាមភូមិសាស្ត្រខេត្ត ក្នុងរយៈពេល១៥ថ្ងៃមុនការចាប់ផ្តើមបើកការដ្ឋានសាងសង់ ដំឡើង ឬរុះរើ ដោយភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដូចខាងក្រោម ៖

- លិខិតជូនដំណឹងទៅមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត តាមទម្រង់ដូចមានក្នុង(**ឧបសម្ព័ន្ធទី១**)
- ច្បាប់ចម្លងឯកសារអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ឬអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា ឬអាជ្ញាបណ្ណផ្តល់សេវាអ៊ិនធឺណិតនិង/ឬអាជ្ញាបណ្ណពាក់ព័ន្ធផ្សេងទៀតដែលផ្តល់ដោយនិយ័តករទូរគមនាគមន៍កម្ពុជា
- ច្បាប់ចម្លងឯកសារអាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុ ផ្តល់ដោយនិយ័តករទូរគមនាគមន៍កម្ពុជា (នៅមានសុពលភាព)
- ច្បាប់ចម្លងឯកសារលិខិតអនុញ្ញាតសាងសង់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍គ្រប់ប្រភេទផ្តល់ដោយនិយ័តករទូរគមនាគមន៍កម្ពុជា
- ច្បាប់ចម្លងឯកសារលិខិតអនុញ្ញាតសាងសង់ ដំឡើង ឬរុះរើ ដែលផ្តល់ដោយរដ្ឋបាលខេត្ត និង/ឬអង្គភាពពាក់ព័ន្ធ
- ច្បាប់ចម្លងឯកសារពាក់ព័ន្ធនឹងសិទ្ធិប្រើប្រាស់ដីស្របច្បាប់ ឬ ឯកសារកិច្ចសន្យា ជួលដីឬផ្ទះ ដើម្បីសាងសង់ ឬដំឡើងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍
- ច្បាប់ចម្លង ឯកសារស្តីពីប្លង់បច្ចេកទេសដែលសមត្ថកិច្ចជំនាញបានពិនិត្យ និងអនុម័ត រួមមាន ប្លង់បាត, ប្លង់មើលចំពីមុខ, ប្លង់មើលពីចំហៀង, ប្លង់គ្រឹះសំណង់, ទម្រង់អង់តែន, គ្រឿងបង្គុំអង់តែន ដ្យាក្រាមការតភ្ជាប់ប្រព័ន្ធចរន្តអគ្គិសនី (ភ្លើង), ប្រព័ន្ធទឹកស្អាត ទឹកកខ្វក់, ប្រព័ន្ធបច្ចេកទេសទូរគមនាគមន៍ និងប្រព័ន្ធបច្ចេកទេសដទៃទៀត។

**ប្រការ ៥.**

មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត មានភារកិច្ច៖

- ពិនិត្យ តាមដាន និងផ្ទៀងផ្ទាត់ការអនុវត្តគម្រោង នៃការសាងសង់ ដំឡើងឬរុះរើ ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍របស់ប្រតិបត្តិករទូរគមនាគមន៍ និងក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណិត
- កត់ត្រាទិន្នន័យព័ត៌មានបច្ចេកទេសឱ្យបានត្រឹមត្រូវច្បាស់លាស់និងធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃការសាងសង់ ដំឡើង រុះរើហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជូនមកអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍នៅរៀងរាល់៣ខែម្តងតាមទម្រង់ដូចមានក្នុង( **ឧបសម្ព័ន្ធទី២**)
- សហការជាមួយអង្គភាព ឬស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធ បញ្ឈប់ការសាងសង់ ឬឃាត់ទុកនូវគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ ក្នុងករណីប្រតិបត្តិករទូរគមនាគមន៍ និងក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណិតមិនបានអនុវត្តតាម ប្រការ៤ នឹងធ្វើរបាយការណ៍ជូនក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីមានវិធានការតាមនីតិវិធីច្បាប់ ។

**ប្រការ៦.**

ប្រតិបត្តិករទូរគមនាគមន៍ និងក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណិតទាំងអស់ ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់។ ក្នុងករណីមិនអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ត្រូវទទួលការផាកពិន័យស្របតាមច្បាប់ស្តីពីទូរគមនាគមន៍ និងបទប្បញ្ញត្តិផ្សេងៗទៀតជាធរមាន។

**ប្រការ៧.**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨.**

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល អគ្គនាយកប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គនាយកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន អគារធិការ ប្រធានវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង គ្រប់ប្រធានមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត ប្រធានអង្គភាពទាំងអស់ក្រោមឱវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងប្រតិបត្តិករទូរគមនាគមន៍ និងក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណិតទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ៕

ថ្ងៃ ព្រហ ៧កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងព័ត៌មាន
- រដ្ឋលេខាធិការអាកាសចរស៊ីវិល
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលាខេត្ត

  "ដើម្បីជូនជ្រាប"
- ដូចប្រការ៨
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឈ្មោះក្រុមហ៊ុន
លេខ.......................

គោរពជូន

**លោក/លោកស្រី ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្ត........................**

**កម្មវត្ថុ** ៖ ស្តីពីការ [សាងសង់] /[ដំឡើង] / [រុះរើ] / [.............] ស្ថិតនៅ [អាសយដ្ឋាន៖ ផ្ទះលេខ .......... ផ្លូវ ..................ភូមិ ឃុំ/សង្កាត់.......................... ស្រុក/ក្រុង ................. ខេត្ត...................................] ។

**ភ្ជាប់ជូន៖**
- ច្បាប់ចម្លងឯកសារអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ អាជ្ញាបណ្ណវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ(នៅមានសុពលភាព) អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា អាជ្ញាបណ្ណផ្តល់សេវាអ៊ិនធឺណិតនិងអាជ្ញាបណ្ណពាក់ព័ន្ធផ្សេងទៀតផ្តល់ដោយនិយ័តករទូរគមនាគមន៍កម្ពុជា
- ច្បាប់ចម្លងឯកសារលិខិតអនុញ្ញាតសាងសង់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍គ្រប់ប្រភេទផ្តល់ដោយនិយ័តករទូរគមនាគមន៍កម្ពុជា
- ច្បាប់ចម្លងឯកសារលិខិតអនុញ្ញាតសាងសង់ ដំឡើង ឬរុះរើ ដែលផ្តល់ដោយរដ្ឋបាលខេត្ត និង/ឬ អង្គភាពពាក់ព័ន្ធ
- ច្បាប់ចម្លងឯកសារពាក់ព័ន្ធនឹងសិទ្ធិប្រើប្រាស់ដីស្របច្បាប់ ឬឯកសារកិច្ចសន្យា ជួលដី ឬផ្ទះ ដើម្បីសាងសង់ ឬដំឡើងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍
- ច្បាប់ចម្លងឯកសារស្តីពីប្លង់បច្ចេកទេសដែលសមត្ថកិច្ចជំនាញបានពិនិត្យ និងអនុម័តដោយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ច្បាប់ចម្លងវិញ្ញាបនបត្រស្តីពីការទទួលស្គាល់យថាប្រភេទនៃគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និងវិទ្យុគមនាគមន៍ លេខ..............ចេញដោយនិយ័តករទូរគមនាគមន៍កម្ពុជាចុះថ្ងៃទី..........ខែ.............ឆ្នាំ....................។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំមានកិត្តិយស សូមជម្រាបជូនលោក/លោកស្រីប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ មេត្តាជ្រាបថា ក្រុមហ៊ុន.......................................................នឹងចាប់ផ្តើមអនុវត្តគម្រោងស្តីពី..............................................................................................................................................................................................................................................................។

គោលបំណងនៃការអនុវត្តគម្រោងនេះគឺដើម្បី..........................................................................................................................................................................................................................................។

(សូមភ្ជាប់ជូននូវព័ត៌មានអំពីគម្រោងជាឧបសម្ព័ន្ធ)

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក/លោកស្រីប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្ត............................... មេត្តាជ្រាបជាព័ត៌មានដោយអនុគ្រោះ។

សូមលោក/លោកស្រីប្រធានមន្ទីរ មេត្តាទទួលនូវការគោរពរាប់អានពីខ្ញុំបាទ/នាងខ្ញុំ៕

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦

ធ្វើនៅ.............ថ្ងៃទី........ខែ..........ឆ្នាំ..........

**ប្រធានក្រុមហ៊ុន**



ឧបសម្ព័ន្ធ-១-

# ព័ត៌មានអំពីគម្រោង

## ក.ព័ត៌មានទូទៅ និងវិសាលភាពនៃគម្រោង

| | |
|---|---|
| - ប្រភេទគម្រោង | ☐ សាងសង់ហេដ្ឋារចនាសម្ព័ន្ធ ថ្មី<br>☐ ដំឡើងឬបំពាក់បន្ថែម<br>☐ ផ្សេងៗ |
| - តំបន់អនុវត្តគម្រោង | ❖ ទីតាំងភូមិសាស្ត្រស្ថិតនៅភូមិ..................................<br>ឃុំ/សង្កាត់........................ ស្រុក/ក្រុង........................<br>ខេត្ត..................................................................... |
| | ❖ កូអរដោនេភូមិសាស្ត្រ ៖<br>Latitude : ..........................<br>Longitude : .......................... |
| | ❖ លេខកូដសម្គាល់អត្តសញ្ញាណទីតាំងស្ថានីយ៍ (Site code/Identification៖.................................... |
| - ពេលវេលាអនុវត្តគម្រោង | ❖ កាលបរិច្ឆេទចាប់ផ្តើមគម្រោង / /<br>❖ ប៉ាន់ស្មានបញ្ចប់គម្រោងក្នុងរយៈពេល ...............ខែ |
| - ការអនុវត្តគម្រោង | ☐ ដោយក្រុមហ៊ុនផ្ទាល់<br>☐ ដោយក្រុមហ៊ុនម៉ៅការ ........................................<br>.......................................................................<br>(ត្រូវភ្ជាប់មកជាមួយបណ្ណប៉ាតង់ដែលនៅមានសុពលភាព) |
| - ព័ត៌មានអំពីអ្នកទទួលខុសត្រូវគម្រោង | ❖ ឈ្មោះអ្នកទទួលខុសត្រូវគម្រោង<br>....................................................... ភេទ.........<br>អាយុ.....................សញ្ជាតិ.................................<br>លេខអត្តសញ្ញាណបណ្ណ ឬ លេខលិខិតឆ្លងដែន<br>.......................................................................<br>❖ ទូរស័ព្ទទាក់ទង ៖.............................................<br>❖ អាសយដ្ឋានអ៊ីម៉ែល៖...........................................<br>....................................................................... |

## ខ. ព័ត៌មានបច្ចេកទេស

| – ប្រភេទហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ | |
|---|---|
| ☐បណ្តាញខ្សែកាប្លិ៍............................ [អុបទិក], [ទង់ដែង],[Co-axial] ឬ [ខ្សែកាប្លិ៍ក្រោមបាតសមុទ្រ] | ☐ ខ្សែកាប្លិ៍អាកាស ☐ ខ្សែកាប្លិ៍អូសក្នុងបំពង់<br>☐ ខ្សែកាប្លិ៍កប់ផ្ទាល់ដី ☐ ប្រភេទបណ្តាញផ្សេងទៀត<br>☐ ប្រវែងខ្សែកាប្លិ៍សរុប៖<br>☐ ប្រភេទខ្សែកាប្លិ៍ FE (Figure Eight)<br>☐ ប្រភេទខ្សែកាប្លិ៍ ADSS<br>☐ ចំនួនគូរនៃខ្សែកាប្លិ៍ទង់ដែង៖<br>☐ ចំនួនសរសៃអុបទិក ៖<br>☐ ITU-T G.652<br>☐ ITU-T G.655<br>☐ ITU-T G.657<br>☐ ប្លង់តម្រុយខ្សែកាប្លិ៍ (As-Built Drawings)<br>☐ ទំហំដីសាងសង់ស្ថានីយ៍<br>☐ ក្រឡាផ្ទៃសរុបអគារស្ថានីយ៍ ....................... ម$^2$<br>☐ កម្ពស់អគារស្ថានីយ៍៖.......ជាន់ ស្មើនឹង...........ម |
| ☐បង្គោលអង់តែនសង់ផ្ទាល់ដី | ☐ ប្រភេទបង្គោលអង់តែន Self Supporting Tower<br>☐ ប្រភេទបង្គោលអង់តែន Guy Supported Tower<br>☐ កម្ពស់បង្គោលអង់តែន(គិតពីផ្ទៃដី)៖............ម<br>☐ ក្រឡាផ្ទៃដីស្ថានីយ៍៖..................................ម$^2$<br>☐ កម្ពស់អគារស្ថានីយ៍៖......ជាន់ ស្មើនឹង...........ម<br>☐ ក្រឡាផ្ទៃសរុបអគារស្ថានីយ៍ ......................ម$^2$<br>☐ វិធីសាស្ត្រដំឡើង/រុះរើ (ប្រសិនបើមាន) |
| ☐បង្គោលអង់តែនសង់លើសំណង់មានស្រាប់ | ☐ ប្រភេទបង្គោលអង់តែន Self Supporting Tower<br>☐ ប្រភេទបង្គោលអង់តែន Guy Supported Tower<br>☐ កម្ពស់បង្គោលអង់តែន(គិតពីផ្ទៃដី)៖............ម<br>☐ កម្ពស់បង្គោលអង់តែន(គិតពីដំបូលសំណង់មានស្រាប់)៖................ម<br>☐ ទំហំបន្ទប់ស្ថានីយ៍៖.......ម x ......ម |

| | |
|---|---|
| | ☐ វិធីសាស្ត្រដំឡើង/រុះរើ ( ប្រសិនបើមាន ) |
| – ប្រភេទគ្រឿងបរិក្ខារ ដែលត្រូវបំពាក់ ដំឡើង/រុះរើ | |
| ☐ ស្ថានីយ៍ផ្សាយ/ទទួល និងបរិក្ខារទូរគមនាគមន៍ | ☐ ម៉ាស៊ីនផ្សាយទទួល(Tx/Rx) Power៖.................<br>☐ មាយក្រូវ៉េវ (MW) Frequency ៖..................<br>☐ BTS, Power៖................................................<br>☐ BSC<br>☐ MSC<br>☐ PSTN<br>☐ IGW<br>☐ Landing Station |
| ☐ ប្រភេទអង់តែនត្រូវដំឡើង/រុះរើ | ☐ អង់តែនទូរស័ព្ទចល័ត 2G ចំនួន .................គ្រឿង<br>☐ អង់តែនទូរស័ព្ទចល័ត 3G ចំនួន .................គ្រឿង<br>☐ អង់តែនទូរស័ព្ទចល័ត 4G ចំនួន ..................គ្រឿង<br>☐ អង់តែន Microwave ចំនួន ......................គ្រឿង<br>☐ អង់តែនផ្សេង ចំនួន .................................គ្រឿង |
| ☐ បរិក្ខារបន្ទាប់បន្សំត្រូវដំឡើង/រុះរើ | ☐ ប្រព័ន្ធខ្សែដី ( Earthing/Grounding System ) សម្រាប់បរិក្ខារទូរគមនាគមន៍<br>☐ ប្រព័ន្ធការពាររន្ទះ ( Lightning Protection System )<br>☐ អំពូលភ្លើងសញ្ញាសម្គាល់ឧបសគ្គ ( Obstruction Lighting ) |

ខ្ញុំសូមប្រកាសថាព័ត៌មានទាំងអស់ដែលបានផ្តល់ជូននៅក្នុងពាក្យសុំនេះគឺពិតជាត្រឹមត្រូវប្រាកដមែន។

ធ្វើនៅ...............................ថ្ងៃទី..........ខែ............ឆ្នាំ.............

**ប្រធានក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍
ខេត្ត ....................................
លេខ.......................

**គោរពជូន**

**ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍**

**កម្មវត្ថុ** ៖ របាយការណ៍ស្តីពីចំនួនបង្គោលអង់តែន ចំនួនអង់តែន និងឧបករណ៍ បរិក្ខារទូរគមនាគមន៍ ដែលបានប្រើប្រាស់នៅក្នុងភូមិសាស្ត្រខេត្ត.............................. គិតត្រឹម ថ្ងៃទី.......ខែ...... ឆ្នាំ..........។

**កម្មវត្ថុ** ៖ ប្រកាសលេខ.........បទ.ប្រក ចុះថ្ងៃ.........................ខែ........ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី.............ខែ...........ឆ្នាំ.......... របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំមានសូមគោរពជូន**ឯកឧត្តមអគ្គនាយក** មេត្តាជ្រាបថា មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត.......................បានធ្វើបច្ចុប្បន្នភាពបង្គោលអង់តែន អង់តែន និងឧបករណ៍, បរិក្ខារទូរគមនាគមន៍ និងពត៌មានវិទ្យា ដែលបានប្រើប្រាស់នៅក្នុងភូមិសាស្ត្រខេត្ត គិតត្រឹមថ្ងៃទី...........ខែ..........ឆ្នាំ............ ដូចមានក្នុងតារាងឧបសម្ព័ន្ធជូនភ្ជាប់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គនាយក** មេត្តាជ្រាបជារបាយការណ៍ និងមានវិធានការបន្តដោយអនុគ្រោះ។

សូម **ឯកឧត្តម** មេត្តាទទួលនូវគោរវកិច្ចពីខ្ញុំបាទ/នាងខ្ញុំ៕

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦២
ធ្វើនៅ..........................ថ្ងៃទី.........ខែ...........ឆ្នាំ..........

**ប្រធានមន្ទីរ**



ឧបសម្ព័ន្ធ-២

## តារាងបច្ចុប្បន្នភាពហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍

## នៅក្នុងភូមិសាស្ត្រខេត្ត................................ គិតត្រឹមថ្ងៃទី...........ខែ...........ឆ្នាំ.............

| ល.រ. | ឈ្មោះក្រុមហ៊ុន | ចំនួនបង្គោលអង់តែន | | | ចំនួនអង់តែនទូរស័ព្ទចល័ត ( * ) | | | ចំនួនអង់តែន Microwave( ** ) | | | បណ្តាញខ្សែកាប្លិ៍ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មានស្រាប់ | សង់ថ្មី | សរុប | មានស្រាប់ | បំពាក់ថ្មី | សរុប | មានស្រាប់ | បំពាក់ថ្មី | សរុប | មានស្រាប់ | ថ្មី | សរុប |
| 1 | | | | | | | | | | | | | |
| 2 | | | | | | | | | | | | | |
| 3 | | | | | | | | | | | | | |
| 4 | | | | | | | | | | | | | |
| 5 | | | | | | | | | | | | | |
| 6 | | | | | | | | | | | | | |
| 7 | | | | | | | | | | | | | |
| 8 | | | | | | | | | | | | | |
| 9 | | | | | | | | | | | | | |
| 10 | | | | | | | | | | | | | |

ធ្វើនៅ.........................ថ្ងៃទី........ខែ..........ឆ្នាំ..........

**ប្រធានមន្ទីរ**

**<u>កំណត់ចំណាំ៖</u>**

- ( * ) ចំនួនអង់តែនទូរស័ព្ទចល័តដែលភ្ជាប់បរិក្ខារម៉ាស៊ីនផ្សាយ/ទទួល ( Tx/Rx )
- ( ** ) ចំនួនអង់តែន Microwave ដែលភ្ជាប់បរិក្ខារទូរគមនាគមន៍វិទ្យុផ្សាយបន្ត